# FATHER FRIENDLY LONG BEACH

## Why Dad Matters

## <u>គ្រឹះស្ថាន</u>

ប្រតិបត្តិគ្រឹះស្ថាននានា ៖

1) **លើកទឹកចិត្តឪពុក ដែលមានសាវតាផ្នែកវប្បធម៌ ផ្សេងៗ គ្នា (បុគ្គលិក និង អតិថិជន) ឱ្យកែខៃ កម្មវិធី សេវា ព្រមទាំង គោលការណ៍ និង នីតិវិធីនានា ដែលមានស្រាប់ របស់ក្រុមហ៊ុន ។**

   *ឧទាហរណ៍ ៖ តើគ្រឹះស្ថាន របស់លោកអ្នកមានដំណើរការ សម្រាប់ទទួល និងរួមបញ្ចូល ព័ត៌មានត្រឡប់ ស្តីពីបិតុមេត្រីភាព របស់គ្រឹះស្ថានលោកអ្នក ដែរឬទេ ?*
   *ឧទាហរណ៍ ៖ តើគ្រឹះស្ថានរបស់លោកអ្នក លើកកម្ពស់ប្រតិបត្តិបិតុមេត្រី សម្រាប់បុគ្គលិក របស់លោកអ្នក ដែរឬទេ ? ឧទាហរណ៍ ការផ្តល់ ពេលវេលា មានលក្ខណៈបត់បែនបាន ដើម្បីឱ្យឪពុក អាចចូលរួម ក្នុងព្រឹត្តិការណ៍នានា នៅសាលារៀន ឬ ក្នុងសកម្មភាពក្រៅកម្មវិធីសិក្សានានា បាន ។*

2) **យក ធនធាននានា ចំពោះប្រភពផ្តល់មូលនិធិ ដែលអាចទទួលបាន សម្រាប់កម្មវិធី និងកិច្ចខិតខំប្រឹងប្រែង លើការចូលរួម របស់ឪពុក ផ្សេងៗ ទៀត ។**

   *ឧទាហរណ៍ ៖ តើយើង ក្នុងនាមជាគ្រឹះស្ថានមួយ កំពុងស្វែងរក ឱកាសទទួលបានមូលនិធិ ដើម្បីជួយគាំទ្រដល់ ការចូលរួម របស់ឪពុក ដែរឬទេ ? ឧទាហរណ៍ ៖ តើគ្រឹះស្ថាន របស់យើង មានយល់ដឹង អំពីឱកាសទទួលបានមូលនិធិ ផ្សេងៗ សម្រាប់ការងារពាក់ព័ន្ធ នឹងការចូលរួម របស់ឪពុក នៅកម្រិតមូលដ្ឋាន និងកម្រិតសហព័ន្ធ ដែរឬទេ ?*

3) **ធ្វើការប្រាស្រ័យទាក់ទងថា «មានការស្វាគមន៍ឪពុក នៅទីនេះ» ហើយមានជ្រើសរើស ឪពុកឱ្យចូលបម្រើការងារ ប្រកបដោយជោគជ័យ ទៅក្នុង**
   **គ្រឹះស្ថាន របស់លោកអ្នក ។**

   *ឧទាហរណ៍ ៖ តើយើង ក្នុងនាមជាគ្រឹះស្ថានមួយ មានចេតនាខ្ពស់ប៉ុណ្ណា ចំពោះការធ្វើឱ្យប្រាកដថា មានវត្ថុបិតុមេត្រី នៅក្នុង គ្រឹះស្ថាន របស់យើង ? នេះអាចរួមមាន តែមិនកំណត់ត្រឹម តុផ្លាស់កន្ទប នៅក្នុងបន្ទប់ទឹក ឯកសារអំណាន (ដូចជា សៀវភៅ ទស្សនាវដ្តី និង ឯកសារអក្សរសាស្ត្រ ផ្សេងៗ ទៀត) ដែលផ្តោតលើ ឪពុក/បុរស ។*
   *ឧទាហរណ៍ ៖ តើមាន រូបភាពវិជ្ជមានរបស់ឪពុក តាំងបង្ហាញ នៅទូទាំងគ្រឹះស្ថាន របស់លោកអ្នក ដែរឬទេ ?*

4) អនុវត្ត យុទ្ធសាស្ត្រវាស់វែង ប្រកបដោយប្រសិទ្ធភាព សម្រាប់ការវាយតម្លៃ កិច្ចខិតខំប្រឹងប្រែង/លទ្ធផល លក្ខណៈបិតុមេត្រី ។

*ឧទាហរណ៍ ៖ តើលោកអ្នកតាមដាន ការចូលរួមរបស់ឪពុក/លទ្ធផលនានា នៅក្នុងគ្រឹះស្ថាន របស់លោកអ្នក បានដោយរបៀបណាដែរ ?*
*ឧទាហរណ៍ ៖ តើលោកអ្នក វាស់វែងប្រសិទ្ធភាព របស់សេវាបិតុមេត្រី ដែលគ្រឹះស្ថាន របស់លោកអ្នក ផ្តល់ឱ្យ បានដោយរបៀបណាដែរ ?*

5) ជំរុញ ភាគីពាក់ព័ន្ធ ដែលមិនមែនជាបុគ្គលិក នៅក្នុងគ្រឹះស្ថាន របស់យើង (ដូចជា សមាជិកគណៈនាយក និង ស្ថាបនិក) ឱ្យយល់ដឹង អំពីសារៈសំខាន់ របស់ឪពុកដែលបម្រើការងារ និង របស់ឪពុក ចំពោះសុខមាលភាព របស់កូន ។

*ឧទាហរណ៍ ៖ តើគណៈនាយក ឬ ស្ថាបនិក របស់លោកអ្នក យល់ដឹង អំពីសារៈសំខាន់ នៃការចូលរួមពីឪពុក ដែរឬទេ ?*
*ឧទាហរណ៍ ៖ តើគណៈនាយក របស់លោកអ្នក គាំទ្រដល់ការបង្កើត ប្រតិបត្តិបិតុមេត្រី នៅទូទាំងគ្រឹះស្ថាន ដែរឬទេ ?*

ខែមីនា ឆ្នាំ 2019